# ទភាគអំពីដំណោះស្រាយបញ្ហាខ្មែរក្នុងយុទ្ធសាស្ត្រកុម្មុយនិស្តចិនយួនទ្ធសាសនា នៅស្រុកខ្មែរ



**Par Sangha OP**

1988

## មាតិការឿង

អារម្ភកថា 1
យុទ្ធសាស្ត្រកុម្មុយនិស្ត នៅ ឥណ្ឌូចិន 3
យុទ្ធសាស្ត្រ សម្ដេច សីហនុ 16
ចប់ 22



## អារម្ភកថា

សិក្ខាសាលាធ្វើឡើងក្នុងកំឡុងឆ្នាំ១៩៨៨ របស់ចលនា «**មូលខ្មែរដើម្បីសេរីភាព**» វិភាគអំពីដំណោះស្រាយបញ្ហាខ្មែរ ក្នុងយុទ្ធសាស្ត្រកុម្មុយនិស្តចិនយួន។ ចលនា «មូលខ្មែរដើម្បីសេរីភាព» ជាចលនាប្រឆាំងនឹង លទ្ធិកុម្មុយនិស្ត បង្កើតឡើង ក្នុងកំឡុង ឆ្នាំ១៩៨៨ ដើម្បីផ្សាយពន្យល់ ដល់ ព្រជាពលរដ្ឋខ្មែរ ពីយុទ្ធសាស្ត្រកុម្មុយនិស្ត ចិន/យួន ដែលជាយុទ្ធសាស្ត្ររំលាយប្រជាជាតិនឹងប្រជាជនខ្មែរ។

ចលនានេះ បានបញ្ចប់សកម្មភាពខ្លួន ក្នុងកំឡុងឆ្នាំ១៩៩៣ ទុកសិទ្ធិសេរីភាព អោយសមាជិកខ្លួនមានសេរីភាពគ្រប់គ្រាន់ចូលធ្វើសកម្មភាពនយោបាយនៅក្នុងគណបក្សនយោបាយនានា ក្នុងប្រទេស ដែលគោរពគោលការណ៍របស់ចលនា។

ឯកសារនេះ បានរៀបចំនឹងសំរួលឡើងដោយ វរសេនីយឯក ហេង ផុន[1] និង ឧប សៅ សង្ហា នៅទីក្រុងបារីស ថ្ងៃទី៨ ខែវិច្ឆកា ឆ្នាំ១៩៨៨។

ខ្មែរអ្នកសាធារណៈរដ្ឋ ដែលបានចូលរួមចំណែកក្នុងសិក្ខាសាលានេះ សូមបួងសួងដល់វិញ្ញាណក្ខន្ធ លោក វរសេនីយឯក ហេង ផុត ដែលលោកបានចូលមរណភាពជាកូនខ្មែរអ្នកជា រក្សាឧត្តមគតិជាខ្មែរ ស្រឡាញ់ របបសាធារណរដ្ឋនិយម លទ្ធិប្រជាធិបតេយ្យសេរី រហូតដល់ ដង្ហើមចុងក្រោយរបស់លោក អោយវិញ្ញាណ លោកជួបតែសេចក្ដីសុខជានិរន្តរ គ្រប់ជាតិកំណើតរបស់លោក។

យើង យកឯកសារនេះ មកផ្សាយឡើងវិញ ទី១ ក្នុង ទំហំ PDF ដើម្បី អោយ អ្នកអានអានបានស្រួល ទី២ ទុកជា ការកំណត់ចំណាំ នៃស្មារតី ខ្មែរមានសេរី និង អ្នកសាធារណរដ្ឋនិយម ធ្លាប់ប្រយុទ្ធ ប្រឆាំងនឹង ពួកកុម្មុយនិស្ត នៅ ឥណ្ឌូចិន ដើម្បី ការពារ ឯករាជ្យជាតិ បូរណភាពទឹកដីកម្ពុជា។ ឯកសារនេះ ជា ស្តូប សំរាប់ រំឭក វិញ្ញាណក្ខន្ធ គ្រប់អ្នកស្នេហាជាតិខ្មែរ ដែលបានបូរជាជីវិត ការពារជាតិមាតុភូមិ ដើម្បី កម្ពុជា សេរី ចំរើនលូតលាស់។ ទោះបីសព្វថ្ងៃ ប្រទេសខ្មែរ នៅរស់ក្រោម របបកុម្មុយនិស្ត និងក្រោមអាណានិគន៍យៀកណាម តែប្រជាពលរដ្ឋខ្មែរ មិនដែលអស់សង្ឃឹមនៅឡើយ។ សេចក្ដីមាន

---

[1] វរសេនីយឯក ហេង ផុតៈ សិស្សនាយទាហ៊ាន ជំនាន់ទី១០ (ជំនាន់ លោក ឧត្តមសេនីយ ដៀន ដែល និង អ៊ិត សួង) បេសកកម្មសឹក ចុងក្រោយ របស់លោក ក្នុង សម័យ សាធារណរដ្ឋខ្មែរ គឺជា មេបញ្ជាការសឹកខេត្ត កោះកុង។

សង្ឃឹមនេះហើយ ជា កម្លាំងខ្មែរដែលនាំបង្កើត សេចក្ដីក្លាហាន ហ៊ានប្រឈមមុខ ខ្ទាំង ជាតិ គ្រប់រូបភាព។

ជយោ ប្រជាពលរដ្ឋខ្មែរ ! ជយោ ស្រុកខ្មែរ !



## យុទ្ធសាស្ត្រកុម្មុយនិស្ត នៅ ឥណ្ឌូចិន

### យុទ្ធសាស្ត្រ យួន ចិន កុម្មុនិស្ត

សាធារណៈរដ្ឋ សង្គមនិយមយៀកណាម (ស.ស.យ.) បានឈ្លានពានកម្ពុជាតាំងពីឆ្នាំ ១៩៧៩ រំលំរដ្ឋ «កម្ពុជាប្រជាធិបតេយ្យ» របបកុម្មុយនិស្តផ្តាច់ការ ប្រល័យពូជសាស្ត្រខ្មែរ ក្នុងនាម ការតព្វកិច្ចអន្តរជាតិ សាមគ្គីភាតរៈភាព និង ទំនាក់ទំនងពិសេស «ចាត់ទុកជា កែវភ្នែក រវាង ខ្មែរ យៀកណាម លាវ ជាបងប្អូនរំដោះកម្ពុជាជា បងប្អូនអោយផុតពី បនប្រល័យពូជសាស្ត្រខ្មែរ ប៉ុល ពត អៀង សារី និង សុន សេន។ ព្រមជាមួយនោះ វាបន្តុប រដ្ឋអំណាចថ្មី «សាធារណៈរដ្ឋ ប្រជាមានិតកម្ពុជា» ដំឡើង ខ្មែរយៀកមុីញអតិតៈ ក្របខ័ន្ត «កម្ពុជាប្រជាធិបតេយ្យ» បន ហេង សំរិន ប៉ែន សូវ៉ាន់ និង ហ៊ុន សេន ជាស្នូលនៃសាធារណៈរដ្ឋនេះ។

«សាធារណៈរដ្ឋ ប្រជាមានិតកម្ពុជា» នេះ ជាមាត់ប្រឹសទ្រូ «សហពន្ធឥណ្ឌូចិន» ដែលកម្ពុជា និង លាវ ត្រូវរិបបញ្ចូលក្នុងទ្រុង «មហារដ្ឋយៀកណាម» មហិច្ឆតា របស់ព្រះចៅអធិរាជ្យ ក្រុងវេតាំង ពីសត្តវត្សទី១៧។

ហូ ជីមុីញ គ្រាន់តែ ជួសជុល កែរលំអ ទ្រុងនេះ ជា «សហពន្ធឥណ្ឌូចិន» នៅពេលគាត់ចាក់គ្រឹសស្ថាបនាប័ក្ខ កុម្មុយនិស្តឥណ្ឌូចិន កាលពីឆ្នាំ ១៩៣០ ប៉ុណ្ណោះ។ កាលសង្គ្រាមឥណ្ឌូចិន លើកទី១ បន្ទាប់ពី សង្គ្រាមសកលលោក លើកទី២ នាឆ្នាំ ១៩៤៦-១៩៤៧ ហូ ជីមុីញ ដោយមាន យ៉ ង្វៀងយ៉ាប់ ជា មេបញ្ជាការសឹក បានលាតសន្ទឹង លានប្រយុទ្ធសាស្ត្រ ពាសពេញដែនដីឥណ្ឌូចិនបារាំង្ស រហូតដល់ លាវ និងកម្ពុជា ច្បាំងតទល់នឹងបារាំង្ស សំអាងលេសថា មកជួយ «រំដោះ”លាវ និង កម្ពុជា សំដីដូចគ្នា នឹងពេលឈ្លានពានកម្ពុជា នៅឆ្នាំ ១៩៧៩ តែជាមួយគ្នានោះ យៀកមុីញ យៀកណាមខាងជើង មកធ្វើកុម្មុយនិស្ត ភាវុប្បនីយកម្ម និង យៀកណាម ភាវុប្បនីយកម្ម ប្លន់រិបយក កម្ពុជា និង លាវ បញ្ចូលក្នុងទ្រុង សហពន្ធឥណ្ឌូចិន នេះឯង។

តឹងតាងជាក់ស្តែង គឺ ពេលដែល កម្ពុជា បានឯករាជ បរិបូណ៌ រំដោះពីបារាំង្ស សព្វគ្រប់អស់ហើយ កាលពីឆ្នាំ១៩៥៣ មុនសន្និសិទក្រុងស្ហឺណែវ ឆ្នាំ១៩៥៤ យៀកមុីញ តតព្រមត្រឡប់ ចូលយៀកណាមវិញទេ ទោះបី សម្តេច នរោត្តម សុីហនុ មាន លោក លន់ នល់ ជាមេបញ្ជាសឹក ដំឡើង ប្រត្តិបត្តិការណ៍យោធា «សាមគ្គី» យ៉ាងណាក្តី យៀកមុីញនៅតែក្រាញខាំកកេរ ដីកម្ពុជា ដដែល រហូតដល់ ពេលបន្ទាប់ ពីកិច្ចព្រមព្រៀង ក្រុងស្ហឺណែវ។

«សាធារណៈរដ្ឋ ប្រជាមានិតកម្ពុជា» ឈរជាប់ លើដី កម្ពុជា បាន ដោយសារ តែទ័ពឈ្លានពាន សាធារណៈរដ្ឋ សង្គមនិយមយៀកណាម ប្រមាណ ជា១សែនកន្លះ ជាន់ទឹកដីនេះ និង ប្រជាជាតិខ្មែរ ពន្លិចមិនអោយហើបរួចទឹកដី និង ប្រជាជាតិរំ លោះ និង

ពាយ ស្រាប់ ដោយស្នាដៃ «កម្ពុជាប្រជា ធិបតេយ្យ» ដោយសារតែ ការសម្លុត របស់បរទេស និង ការកម្លាចបាក់ស្បាតស្រាប់ នៃជនជាតិខ្មែរ ដែលរងគ្រោះ ជាទម្ងន់ ពីសំណាក់ «កម្ពុជា ប្រជាធិបតេយ្យ» បើគ្មាន របបក្លែងក្លាយ និង ឧត្តបាទ នេះទេ ម្លេះអ៊ី យៀកណាម នឹងទទួលវាសនា ដូចគ្នានឹង អធិរាជាណាច័ក្រ អាណ្ណាម ពេលទ្រឿង មីញយ៉ាង វាសោយរាជ នៅស្រុកខ្មែរ កាលពី ពាក់កណ្ដាល សត្តវត្សទី១៩ ពេលវាចាប់ព្រះក្សត្រីអង្គមីយ ទៅឃុំ ឯក្រុងវេ៉ សម័យ «កំពប់តែអុង» សម័យយួន វាដុតវត្តអារ៉ាម វាបង្ខំអោយខ្មែរនិយាយភាសារយួន ស្លៀកពាក់យួន ទុកសក់បួង ជាយួន ផ្លាស់ឈ្មោះខេត្តនិង ស្រុកជាយួន ។ល។ នាំ៖ ប្រជាពលរដ្ឋខ្មែរ ទ្រាំលែងបាន ក៏ងើប បះបោរ ប្រឆាំងនឹងយួនទាំងប្រទេស កម្លុងតែ ៣អាទិត្យ កាប់កំចាត់យួន អស់រលីងពីកម្ពុជា។

នេះជាសច្ចៈធម៌ នៃប្រវត្តិសាស្ត្រ មិនបានបង្ហាញថា ជនជាតិតិច ប្រទេសតូចទន់ខ្សោយ គ្មានលទ្ធភាព នឹងការពារ អាយុជីវិតខ្លួន ការពារឯករាជភាព អធិបតីយភាពសេរីភាព របស់ខ្លួន។ យៀកណាមខ្លួនឯង កាលដែលច្បាំងទល់នឹងបារាំងក្ដី ទល់នឹងអាមេរិកាំងក្ដី ហើយ បារាំង និង អាមេរិកាំង មិនមែនតូចតាចទេ ជាមហាអំណាចទៅហើយ តើម្ដេចបានជា យៀកណាម ដណ្ដើម យកជោគជ័យបាន ? តើជោគជ័យនេះមិនមែនជាជោគជ័យ របស់ឯករាជភាព អធិបតីយភាពជាតិ ដូចគ្នានឹង ជោគជ័យរបស់ខ្មែរ សម័យកំពត់តែអុង ទេឬអ្វី ? ឥឡូវនេះ អ្នកណា ជា អាណានិគម ច័ក្រព័ត្រនិយមលើកម្ពុជា ? មិនមែនជា យៀកណាម ឬទេអ្វី ?

អាណានិគមនេះ គ្មានល័ក្ខណៈសម្បត្តិ អរិយៈធម៌ ដូចបារាំងទេ វាព្រៃផ្សៃសាហាវយង់ឃ្នង ទុក «សាធារណៈរដ្ឋ ប្រជាមានិតកម្ពុជា» ដែលមាន រូបភាព ពិត ជាខេត្ត នៃសហព័ន្ធឥណ្ឌូចិន ប៉ុណ្ណោះ គឺជាការ ផុសរឹលត្រឡប់មកវិញ នៃសម័យ «កំពប់តែអុង» យ៉ាងសុទ្ធសាធ ដែល កម្ពុជា ត្រូវរលប់ពីផែនទីភូមិសាស្ត្រ នៃពិភពលោក ដែលប្រជាជាតិខ្មែរ រលាយក្លាយជាជនជាតិយួន ដូចករណីយចាម និង កម្ពុជាក្រោម និងជាតិ ពន្ទុ ម៉ែរម៉យ រដែងអ្នកស្រុកភ្នំ នៃជួរភ្នំអាណ្ណាម ជាមួយគ្នា និង លាវ លិចក្នុងគំនួច «សហព័ន្ធឥណ្ឌូចិន» ដែលមានជនជាតិយៀកណាម ដ៏ច្រើនលើសលប់ ជាជនជាតិអ្នកដឹកនាំ។

យើងដឹងថា អតិតសហភាពសូវៀត ជំនាន់នោះ មានផលប្រយោជន៏រួម ជាមួយ យៀកណាម ក្នុងកិច្ចបង្កើត «សហព័ន្ធឥណ្ឌូចិន» នេះ ព្រោះ ជាផ្នែកភូមិយុទ្ធសាស្ត្រ នៅអាស៊ី អគ្នេយ៏ និង មហាសមុទ្រ ប៉ាស៊ីហ្វិក ភាគខាងត្បូង ដោយ សហភាពសូវៀត នឹងបញ្ជៀត ស៊ិកសៀត តាំងមូលដ្ឋាន នាវា និង អាកាសចរណ៏ ចំបាំង នៅ កាំរ៉ាញ់ ដាណាងនិងកំពង់សោម បានឈមមុខ ទល់នឹង មូលដ្ឋាន យោធា អាមេរិកាំង នៅកោះ គួម ក្លា

រក៍ ហ្វៃលត៍ និង ស៊ុបីកមេយ៍ នៃប្រទេសហ្វីលីព្ពីន ផង ឈមមុខបែរ ទៅចិន ប្រជាមានិតផង។

សហព័ន្ធឥណ្ឌូចិន បាន ជាកូន ប័ក្ខសម្ព័ន្ធ «វ៉ារស្ស៊ូវី» មួយតូច ឈមមុខ ទល់នឹងសម្មាគម ប្រទេសអាស៊ី (អាស៊ាន) កូន ប័ក្ខសម្ព័ន្ធ អូតង់ នៅអាស៊ី។

មើលឃើញ ជំហ៊រមហាអំណាច បដិប័ក្ខកំពូលពិភពលោក ទាំងសង្ខាង ឈររបៀបនេះ ឃើញគំរូ ដោះស្រាយ ករណី ប្រទេស អាហ្វគ្គានីស្តង់ ដោយ សុំគ្រលុំ រវាង មហាអំណាច ដែល លាងសំអាតតែដៃ របស់គេ ចោលដាន ទាំងសង្ខាង គ្មានសន្តិភាព ពិត សង្គ្រាម នៅសង្គ្រាម ដដែលពាក្យ «ក្លាស់ណិសត៍ ភាពថ្លាឆ្វង់ ដូចកញ្ចក់ ជាំរ៉ែត្រុយការ រើស រច្ចនាសម្ព័ន «ការលាបថ្នាំ ប៉ះប៉ូវ នៃរបបសង្កត់សង្កិនឈ្លានពាន សេរីភាព និង សិទ្ធិមនុស្ស នៅសហភាពសូវៀត ការដោះ រំលាយ កាំជ្រួច នុយក្លេះអែរ អ៊ីរ៉ូមីសល៍ មធ្យម ការដកទ័ពសូវៀតចេញពីអាហ្វគ្គានីស្តង់អ្វីៗ ទាំងប៉ុន្មាន គ្មានចំណុចត្រង់ណា ដែលអាចជាសំណល់ ចំហាយដោះស្រាយ វិបត្តិកម្ពុជា ជាជាក់ស្តែង ស្របនឹងឆន្ទៈ របស់ កម្ពុជា បានឡើយ។

ផ្ទុយទៅវិញ យៀកណាម សង្គមនិយម បោះនុយ ប្រកប ដោយពីសពុល។ រឿងយៀកណាម ដកទ័ពចេញពី កម្ពុជា នៅឆ្នាំ១៩៩០ សណ្តំ បន្ទន់ទឹកចិត្ត កម្ពុជា អោយភ្លូកភ្លឹកត្របាក់នុយនេះ រើស មកខាំងណ្តើមគ្នា បែកបាក់គ្នា នាំគ្នា ចូលស៊ីង យៀកណាម បើកទឹកបង្ហូរ ជួយបង្ហឹល រហាត់ទឹក ប្រល័យ សណ្តំ ព្រលឹងជាតិខ្មែរ ខ្លះ សំអាង លើ ភាពមហន្តរាយ សេដ្ឋកិច្ច យៀកណាម ខ្លះទៀត លើ សប្បុរសធម៌ យៀកណាម ភាតរៈភាពយៀកណាម ជាបងប្អូន បញ្ជាក់ខ្លឹមសារ ពាក្យស្លោក «សាម្មគី ជាភាតរៈ ការតព្វកិច្ចអន្តរជាតិ និង ទំនាក់ទំនង ពិសេស «អះអាង ជួយយៀកណាម កំពុង តែប្រឹង យ៉ាងប្រញឹកដៃក្នុងការៈ។

## ១. ផ្ទេរសង្គ្រាមកម្ពុជា អោយក្លាយជា សង្គ្រាមក្នុងស្រុក រវាង ខ្មែរនឹងខ្មែរ

ដោយបង្កើតទ័ព ពង្រឹងទ័ព «សាធារណៈរដ្ឋ ប្រជាមានិត កម្ពុជា» អោយបានជាកងកម្លាំង ជំនួស ទ័ពយៀកណាម បានបម្ងាប់ពី យៀកណាម ដក ទ័ពនៅឆ្នាំ១៩៩០។ ទ័ពនេះ ជ្រើសរើស ភាគច្រើន ក្នុងចំណោម យុវជន កំព្រា ឪពុកម្តាយ ស្លាប់ដោយការប្រល័យស្នាដៃ «កម្ពុជា ប្រជាធិបតេយ្យ» ក្នុងរយៈការណ៍ ឆ្នាំ១៩៧៥-៧៩ ជា យុវជន ដែលទ័ពយៀកណាម ប្រម៉ូលបាន កាលវាចូលមកឈ្លានពាន ដំបូង ក្នុង ឆ្នាំ១៩៧៩ បញ្ជូនទៅអប់រំ នាយទាហ៊ានជាន់ខ្ពស់ នៅសហភាពសូវៀត គ្របខ័ណ្ឌ នាយទាហ៊ានរង អប់រំនៅ យៀកណាម។

- គ្រប់ស្រុក និង ទីប្រជុំជនធំៗ មាន កងវរៈ ក្តាប់ដែនដី កងវរៈ មាន មួយស្រុកមួយ។

- កងប្រជាពលរដ្ឋ ប្រដាប់អាវុធ ជានិគមន៍ជាតិយួន ចូលសញ្ជាតិជាខ្មែរ ដឹកជញ្ជូន ពីយៀកណាម ហើយជា អតីតយោធា យៀកណាម សុទ្ធសាធ មកលាយចំរុះនឹង ប្រជាពលខ្មែរទូទៅ ទាំងអស់គ្នា ងសមៈមាត្រ ៣០% ប្រជាពលខ្មែរ ៧០% ទទួលបន្ទុក ចិញ្ចឹមបីបាច់ ឧបត្ថមផ្គត់ផ្គង់ អ្នកនិគមន៍ថ្មីនេះ ជាបងប្អូន ជាម្ចាស់ មិនអាចហើបមាត់រួចជំទាស់សំអាង ថា យួន ជាខ្មែរ បានទេ ព្រោះនៅក្នុង «សហព័ន្ធឥណ្ឌូចិន» ខ្មែរយួនលាវជាជាតិតែមួយ បងប្អូននឹងគ្នា អ្នកណាលើកបញ្ហា អ្នកជាតិនិយម ចង្អៀតចង្អល់ មកទៀត អ្នកនោះ ជា «ប្រតិកិរិយា» សំណល់ នៃ «សង្គមចាស់» ពុករលួយ ខុសនឹង មាគ៌ា «បដិវតន៍ថ្មី»។

## ២. នយោបាយ យៀកណាម ភាវុប្បនីយកម្ម

ជាពិសេស លើផ្នែកវប្បធម៌ កម្មវិធី សិក្សា ក្នុងសាលា តម្រូវអោយ រៀនអក្សរ ភាសាយួនជាភាសាទី២ បន្ទាប់ខ្មែរ។ ដើម្បីនឹងកាន់តំណែង ជាកូនសោរ ក្នុងរដ្ឋបាល ចេះនិយាយភាសា និង សរសេរអក្សរយួន ជាលក្ខណ: តម្រូវ ហើយ បើមាន ប្រពន្ធ ឬ ប្តីជាជនជាតិយួនទៀត រឹតតែប្រសើរអាចមានអភ័យឯកសិទ្ធលើសគេឯងឯទៀត។ នៅតំបន់ខ្លះ ជាពិសេស ខេត្ត ព្រៃវែង ស្វាយរៀង តាកែវ កំពត បំបិតហាម មិនអោយនិយាយភាសាខ្មែរជាដាច់ខាត។

ផ្នែកប្រវត្តិសាស្ត្រ លើកតែខ្មែរយៀកម៉ិញ មាន សឺង ង៉ុកម៉ិញ ហៅអាចារ្យមាន ទូសាមុតណុបបុភាន ជាវីរៈបុរសដ៏ឆ្នើម «ចរន្តបីទន្លេតែមួយ» ខ្មែរ យៀកណាម លាវ មានដើមកំណើត ពូជពង្សតែមួយ បែកគ្នាច្រើនសត្តវត្ស ដោយពួកស្តេចក្រាញ់ អធិរាជជំនាន់ដើម លោភអំណាច អាណានិគមន៍ ចិន និង បារាំង្ស បរទេសបំបែកបំបាក់ «បងប្អូន» ខ្មែរ យៀកណាម លាវ អោយទាស់ទែងគ្នា ដើម្បីត្រួតជិះជាន់។

យៀកណាមថ្ងៃឆ្លាក់ កែរ វប្បធម៌ អរិយៈធម៌ ប្រវត្តិសាស្ត្រ ពង្រិចពង្រីល ទំនៀមទម្លាប់ប្រពៃណីយខ្មែរ ធ្វើយ៉ាងណា អោយខ្មែរ វង្វេងជាតិឯង អោយបាន ទៅអនាគត ខាងមុខ ប្រជាពលរដ្ឋ សហព័ន្ធឥណ្ឌូចិន ក្លាយជា ជនជាតិ យៀកណាម ទាំងអស់។

៣.ស្ថាបនា មហាកំពែង ព្រំដែន «សហព័ន្ធឥណ្ឌូចិន» និង សមាគម ប្រទេសអាស៊ាន ៖ ព្រំដែនបែកចែក លោកកុម្មុយនិស្ត ដែល លោក រីគ្គាន់ ប្រធានាធិបតី សហរដ្ឋអាមេរិក សន្មត់ហៅថា «ចក្រព័ត្រាធិរាជនៃព្រាយបិសាច» និង លោកសេរី ផែនដី សេរីភាពបន្ទាប់ ពីកិច្ចព្រមព្រៀង ក្រុងស្ហឺណែវ ឆ្នាំ ១៩៥៤ គឺនៅខ្សែស្រប លេខ១៧ ព្រំដែន យៀកណាម ខាងជើង និង ខាងត្បូង។

ឥឡូវនេះ ខ្សែព្រំដែននេះ សំយ៉ុងចុះ ពីចិនប្រជាមានិត ចាក់បណ្តោយ តាមទន្លេមេគង្គសសៀរតាមព្រំដែនលាវថៃ បន្តមក តាមព្រំដែន កម្ពុជាថៃ រហូតដល់ឈូងសមុទ្រសៀ

ម។ ជាការស្លាកស្នាមមួយប្រវែងបណ្ដោយប្រមាណ ៨០០ គ.ម. ចាប់ពីដែនលាវមក។ ជាផ្លូវយុទ្ធសាស្ត្រ ឆ្ការព្រៃ វាលអមសងខាង ប្រមាណ៥០០ម បណ្ដាក់ ដោយ ប៉ុស្តិ៍ប៉ម បង្កប់អន្ទាក់បង្កៃគ្រាប់មីន កន្លែងខ្លះ រថយន្ត បើកបរបាន មានយោធាឃ្លាំ ពីនឹត រក្សា ជាអចិន្ត្រៃអាចមានបណ្ដាញ ប្រដាប់ទំនើប គយឃ្លាំ និងប្ដល់សញ្ញាអាសន្ន។ បន្តពីដែនដីលាវ ដែលមានទន្លេមេគង្គ ជាព្រំដែនធម្មជាតិ។ ជាជញ្ជាំង នៃក្រុងប៉ៃឡាំងទៀត នៅអាស៊ីភាគអគ្នេយ៍ ពុះជ្រៀក ភ្នំក្រវ៉ាញ ស្ទះបិត ច្រកេចញចូល មិនអោយសេរីភាព ចូលកម្ពុជា បាន តាមរយៈ នៃកងតស៊ូរំដោះ។

មហាកំពែងនេះ ចាប់ស្ថាបនា តាំង ពីឆ្នាំ ១៩៨៤ ដោយកេណ្ឌ ប្រជាពលរដ្ឋ បង្ខំអោយធ្វើការយ៉ាងទម្ងន់ ទឹមដូចគោក្របី ប្រចាំការណ៍ជានិច្ច។ អ្នកស្រុកស្លាប់ ក្នុងការស្ថាននេះ ជាង ៥០.០០០ នាក់ ចំណែក អ្នកសេសសល់ ពីស្លាប់ កើតរោគ គ្រុនចាញ់ ទាំងអស់ មិនមែនជាសង្គ្រាម វិត្រាណូ មួយ ដែលសម្លាប់ ប្រជាជាតិខ្មែរ ដោយ មេរោគគ្រុនចាញ់ធម្មជាតិទេឬ ?

តើនៅចុង ឆ្នាំ១៩៩០ ឆ្នាំដែល យៀកណាម ប្រកាសថា បានដកទ័ពចេញពីមហាកំពែងនេះ មិនផុសចេញ ជា រូបភាព ជាក់ស្ដែងទេ ឬអ្វី ?

ផ្ដុំនឹងកិច្ចផ្ទេរ សង្គ្រាម អោយក្លាយ ជាសង្គ្រាម ក្នុងស្រុក ជាមួយគ្នានឹង នយោបាយ យៀកណាមភារូបនីយកម្ម រៀបរាប់ខាងលើ បងប្អូនខ្មែរ «អ្នកជាតិនិយម» អ្នកស្នេហាជាតិទាំងឡាយ អាចវាស់ស្ទង់ទំហំ និង ជម្រៅ ពុតត្បុត របស់យៀកណាម ពិសពុល នៃពាក្យសន្យាប្រកាស ដកកងទ័ពវា នៅឆ្នាំ១៩៩០ ខាងមុខ និង អន្ទាក់ «ចរចា» គ្រប់បែបយ៉ាងលើជំពូក «ផ្សះផ្សាជាតិ» ក្នុងក្របខ័ណ្ឌ រដ្ឋាភិបាល ត្រីភាគី ឬ ចតុភាគី ឬក៏ទ្វេភាគី អ្វីៗដែលសុទ្ធតែ ជាល្បិចបោកប្រាស់ខ្មែរ អោយធ្លាក់ ក្នុងសុបិន និង បែកបាក់គ្នា ប្រញ៉ាយខាំគ្នា ដណ្ដើម ស្រមោល កម្ពុជាឯករាជ្យ អព្យាក្រឹត្យ ឥតក្រហម មិនខៀវ របបសភានិយម សេរីនិយម តាមការស្រមើស្រម៉ៃ របស់ភាគីនិមួយៗ ត្រូវសម្លឹងមើលអោយច្បាស់ នូវករណីយ អាហ្វគ្នានីស្ថង់។ រីឯ កម្ពុជា វាស្មុកស្មាញ លើស អាហ្វគ្នានិស្ថង់ ឆ្ងាយណាស់ ទៅទៀត។ សង្គ្រាមនៅអាហ្វគ្នានីស្ថង់ មានសហភាពសូវៀត ធ្វើផ្ទាល់។ ចំណែក កម្ពុជា យៀកណាម មិនងាយ នឹងអនុវត្តន៍ តាមឧវាទ សហភាពសូវៀតទេ ព្រោះសូវៀត ត្រូវការតាំងមូលដ្ឋាន លើទឹកដី យៀកណាម ម្យ៉ាងទៀត សង្គ្រាម នៅកម្ពុជា ប្លែកពីសង្គ្រាម អាហ្វគ្នានីស្ថង់ ទាំងស្រុង ដោយនៅ កម្ពុជា មិនមែន ជាសង្គ្រាមសេរីការ រំដោះទេ គឺជាសង្គ្រាម រវាង កុម្មុយនិស្តនឹង កុម្មុយនិស្ត រវាង «កម្ពុជា ប្រជាធិបតេយ្យ» កុម្មុយនិស្តនិយមចិននឹង «សាធារណរដ្ឋ ប្រជាមានិតកម្ពុជា» កុម្មុយនិស្តនិយមយៀកណាម និង សហភាពសូវៀត។

«រណៈសិរ្ស រួបរួមជាតិ ដើម្បី កម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិ និង សហប្រតិប័ត្ត» របស់ សម្តេច នរោត្តមស៊ីហនុ និង «រណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរ» របស់ លោក សឺន សាន ជា ភាគី រណប នឹងបន្ថែម របស់រដ្ឋ «កម្ពុជា ប្រជាធិបតេយ្យ» ដែរមាន ស្ថាប័ន នយោបាយ «ស្របច្បាប់» តំកល់អសនៈ នៅអង្គការ សហប្រជាជាតិ មាន ១១៧ ប្រទេស ទទួលស្គាល់ និង គាំទ្រពិតមែន តែរដ្ឋនេះ សល់តែ សំបកទទេ គ្មាន ទឹកដី និង ប្រជាពលរដ្ឋ។

សម្តេច សីហនុ និង លោក ស៊ឺន សាន មិនមែនទ្រង់ និង លោក មិនជ្រាប យ៉ាងច្បាស់ អំពីភាព ឥតកែរប្រែ ផ្លាស់ប្តូរ របស់ខ្មែរក្រហម ភាគី កម្ពុជា ប្រជាធិបតេយ្យ ព្រមទាំង ឥរិយាបទ នៃចិនប្រជាមានិត ដែលជាប់ស្អិត ចាត់ខ្មែរក្រហម ជាកូនសំណប់ចិត្ត ទេ ចិនយល់ថា ខ្មែរក្រហមនេះ ជា «ឆ្មា» ពូកែចាប់ «កណ្តុរ» យៀកណាម ជាងភាគី ឯទៀត ក្នុងភាគីទាំងអស់ នៃរដ្ឋាភិបាល ចំរុះត្រីភាគី។

ព្រោះកណ្តុរ បន្ទាប់ពី យៀកណាម ដែលចិន ត្រូវចាប់ស៊ី គឺ កណ្តុរ «រណៈសិរ្សរួបរួមជាតិ ដើម្បី កម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិ និង សហប្រតិប័ត្ត» និង «រណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរ» នេះតែម្តង។ រណៈសិរ្សទាំងពីរនេះ ជៀសមិនផុត ពី វាសនា រណៈសិរ្សរួបរួមជាតិ កម្ពុជា និង រាជរដ្ឋាភិបាល រួបរួមជាតិ កម្ពុជា ដែលជា អង្គការ នយោបាយចាស់ របស់ សម្តេច សីហនុ និង លោក ប៉ែន នុត នៅក្រុងប៉េកាំង កាលពីសង្គ្រាម៥ឆ្នាំនោះទេ។

ចិនប្រជាមានិត បើកាលណា យៀកណាម ដកទ័ពពិតប្រាកដចេញពី កម្ពុជា ដោយ ប្រការណ៍ចរចារក្តី ដោយសឹកក្តី ចិន មានមធ្យោបាយគ្រប់គ្រាន់ ក្នុងការចងជើង ចងដៃ សម្តេចស៊ីហនុ និង លោក ស៊ឺន សាន អោយ ខ្មែរក្រហម សំពង សម្លាប់ តាមចិត្ត ប្រាថ្នា តាមរយៈ ល្បែងផ្តាច់ ជុំនួយសឹក ជាអាទ៍ ចិន ធ្លាប់ចងដៃចងជើង សម្តេច ស៊ីហនុ នៅឆ្នាំ១៩៧៥ រួចមកហើយ រលំពេលជាមួយគ្នានោះ មិនត្រឹមតែ «សាធារណៈរដ្ឋខ្មែរ» ទេ គឺរលំដោយទាំង ស៊ីហនុនិយម «រណសិរ្ស រួបរួមជាតិ កម្ពុជា និង រាជរដ្ឋាភិបាល រួបរួមជាតិ កម្ពុជា របស់ព្រះអង្គ ដែលជា អ្នកឈ្នះផង ទៅទៀត។

កាលណោះ ខ្មែរក្រហម និង ខ្មែរយៀកម៉ិញ នៅជា បក្ខកុម្មុយនិស្ត និង អង្គការ បដិវតន៍ កម្ពុជា នៅឡើយផង មិនទាន់ឡើងដល់ ថ្នាក់ រដ្ឋកម្ពុជា ប្រជាធិបតេយ្យ នោះទេ តែ វាជាម្ចាស់សមរភូម៌ រីឯ សម្តេច សីហនុ និង លោក ប៉ែន នុត មានតែសំបកអង្គការ ឯ ក្រុងប៉េកាំង ឥឡូវនេះ ចំណុចនេះ នៅតែដដែល ភាគី កម្ពុជា ប្រជាធិបតេយ្យ នៅតែ ក្តាប់សមរភូម៌ទៀត ថែមទាំងជា ម្ចាស់នយោបាយ លើផ្ទៃរា បអន្តរៈជាតិផង។

នៅ អង្គការ សហប្រជាជាតិ មានតែ តំណាង រដ្ឋកម្ពុជាប្រជាធិបតេយ្យ មានតែភ្លេង «ខ្លូងខែក» ជាតិ បន្លឺ មាន តែទង់ជាតិ ក្រហមផ្ទឹនឆ្នៅ ប្រាសរន្ទាល ដោយឈាម ប្រជាជាតិ បក់រវិច គ្មាន រដ្ឋាភិបាល ចំរុះត្រីភាគីទេ រដ្ឋាភិបាលនេះ គ្រាន់តែជា ឧបករណ៍ខ្មៅខ្វង នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យ ប៉ុណ្ណោះ។

សេចក្តីអត្ថាធិប្បាយ យ៉ាងវែងអន្លាយខាងលើ បានបញ្ចាំង មើល សមាសភាព សកម្មភាព នយោបាយ រដ្ឋអំណាច នៃរដ្ឋនេះ មិនទាន់មាន គ្រប់គ្រាន់ទេ រដ្ឋនេះ នៅបង្កប់អាទ៍កំបាំងច្រើនណាស់ សម្តេច សីហនុ ទ្រង់ បាន បរិហារស្ទើ តែសព្វគ្រប់ទាំងអស់ ក្នុងបទវិចារណកថា ចុះផ្សាយ ក្នុងព្រឹត្តប័ត្រប្រចាំខែ នៃឯកសារ របស់ព្រះអង្គ។

សម្តេច ព្រះអង្គឯក ក៏ព្រះអង្គ មិនបានទតឃើញ «កម្ពុជាធិបតេយ្យ» បច្ចុប្បន្ននេះ មានអ្វីប្លែកពី «កម្ពុជាធិបតេយ្យ» កាលពីដំណាក់ការ ឆ្នាំ ១៩៧៥-៧៩ ទេ ទោះបី ភាគីនេះ បានប្រកាស ឃោសនាថាខ្លួន ជំរុះរបបកុម្មុយនិស្ត ចោលហើយ អានាគត កម្ពុជាជាសេរីនិយម សភានិយម ក៏ដោយ ទាំងការ តំកល់ ស្ថាប័ន ដដែល ភ្លេង និង ទង់ជាតិ ដដែល នៅ អង្គការ សហប្រជាជាតិ រច្ចនាសម្ព័ន នយោបាយ យោធា កិច្ចអនុវត្ត លើលានប្រយុទ្ធអ្វីៗ នៅដដែល គ្មានឃើញ កែរប្រែចំណុចមួយណាទេ។

អ្នកសង្កេតការអន្តរជាតិ អង្គការ មនុស្សធម៌ សិទ្ធមនុស្ស អន្តរជាតិ ម្នាក់ងារ យកការណ៏ ពិសេស របស់អាមេរិកាំងព្រមទាំងអ្នកភៀសខ្លួនខ្មែរ តាមជុំរំនានា នៅប្រទេសថៃ ក៏បញ្ជាក់ថា «កម្ពុជាធិបតេយ្យ» នៅតែក្រហមដដែល ឈ្លានពាន សិទ្ធមនុស្ស កាប់សម្លាប់ ធ្វើទារុណកម្ម វាយដំ ច្រមធាក់ បែបពន្ធនាគារ ទួលស្លែង (ស.២១) ដដែល។

របៀបជ្រើសរើស កេណ្ឌកងមនុស្ស បញ្ចូលជា យោធា ក៏ប្រើវិធី កំញើញសម្លុត យក ឪពុកឃុំ អោយកូន ធ្វើការ ទៅច្បាំងលោះ ឬ ឃុំសង្កត់សង្កិត ប្រពន្ធកូន បង អោយ ប្តី ឪពុក ប្អូន ទៅច្បាំងលោះ វិលទៅវិលមក។ ចំណីអាហារណ៏ ជាអាវុធ ជាផ្ដាក់ ទាក់ មនុស្សបញ្ចូន អោយស្លាប់ អ្នកណា មិនអនុវត្ត តាមឱវាទវា វា បង្អត់បាយ មិនចែក «របប» អោយទេ។ នារីក្រមុំ ពេញរូប វាកេណ្ឌ បញ្ចូល ក្នុងអង្គភាព «ខ្សែស្បៀង» វា ជូនកាលទុកជា «រង្វាន់» ផ្អែក កាមតណ្ហា ដល់យុទ្ធជន ដែលមាន វីរៈភាពផង។ ពេលទៅធ្វើ ប្រត្តិបតិការណ៏ ឆាបឆក់ទៅក្នុងភូមិ វាចាប់ជន្លៀស យកមនុស្ស ជាពិសេស យកយុវជន យកមកធ្វើ យោធា ដូច្នេះហើយ បានជា៨ឆ្នាំកន្លងមក វាគ្មានរំដោះ បានដី កម្ពុជា មួយដុំត្រង់ណាសោះ ចេះតែអួតក្អេងក្អាង ខាងចូលជ្រៅដាន់ «អាខ្មាំងយួន» សង្កត់ករវា ជុំវិញទន្លេសាប ជុំវិញភ្នំពេញ មុខក្រាស ឥតអៀនខ្មាស់។

ប៉ុល ពត អៀង សារី សុន សេន ណួន ជា អាម៉ុក សុទ្ធតែបនផ្កាប់មុខ វក់ក្នុងមនោគមន៏កុម្មុយនិស្តដាច់ខាត ពួក «មហាលោភផ្ដេះ មហាអស្ចារ្យ មហាភ្លឺស្វាង» លោភផ្ដេះ

រំលង ដំណាក់ការ សង្គមទាសភាព សង្គមសក្តិភូមិ សង្គមមូលធន ផុតសង្គម សង្គមនិយម ផុតឆ្លងតែមួយផ្លោត ៤ដំណាក់ការ បានដល់ មាត់ទ្វារ ស្ថានសួគ៌ កុម្មុយនិស្តមួយសូម្បីតែ ឡេនីន ស្តាលីន ម៉ៅ ឬ ហូ ជីមិញ លោតឥតបានដល់ ជាយស្ថានសុខ ឥតអ្នកមានអ្នកក្រ សង្គមលែង មានវណ្ណៈ ប្រកបដោយ ពន្លឺ មហាភ្លឺស្វាង គ្មានពោធិសត្វ កុម្មុយនិស្ត អង្គណា បានដល់កន្លែងនេះ ដូច តថាគត អង្គអញ «កម្ពុជាធិបតេយ្យ» ទេ។

សូម្បី តាម៉ៅ ដើងឯក បដិវត្តន៏ វប្បធម៌ ក៏ លោត នៅតែ ចាញ់អញ បំបាត់ វណ្ណៈ អោយរលីង ដូចអញ មិនបានផង ឯចំណែក លោកបង ហូ ជីមិញ នៅជាប់តាំងនឹង សហព័ន្ធឥណ្ឌូចិន ភាំងភ្លេច គម្ពី ម៉ាក្ស-ឡេនីន ស្តីពីការ រំលាយចោល នូវរដ្ឋ ដោះលែងមនុស្សអោយក្លាយ ជាទេវតា ទេពធីតា ទាំងអស់ មើលទៅមួយ ល្អដូចមួយ ស្មើៗគ្នា ក្នុងស្ថានសួគ៌ ស្ថានសុខមួយ ប្រាសចាក សង្គ្រាម ព្រោះគ្មាន បុព្វហេតុអ្វី នឹងមាន បដិវត្តន៏ រវាងគ្នាទៀតទេ ជាសង្គមកុម្មុយនិស្ត ថ្នាក់ខ្ពស់ ប្រកបដោយ យុត្តិធម៌ ត្រាស់សំរេចបាន ពោធិញ្ញាណ យ៉ាងនេះហើយ បានជា «កម្ពុជាធិបតេយ្យ» ទឹម ប្រជាពលរដ្ឋខ្មែរ ដូចគោក្របីទាញភ្ជុំផ្តាប់គ្នា ធ្វើទំនប់ ជីកប្រឡាយ សស្រាក់សស្រាំ អោយ ប្រជាពលរដ្ឋខ្មែរ វាន់កន្ទបប៉ឹង ដូចថៅស្រទបចេក អោយមាន សោភ័នភាព ដូចទេពអប្សរចន្លាក់ លើថ្មអង្គរ រឿងយៀកណាម បញ្ចូល កម្ពុជា ក្នុងសហព័ន្ធឥណ្ឌូចិន ជារឿង កំប៉ិចកំប៉ុក ជារឿង ដែលយៀកណាម នៅល្ងង់ខ្លៅ បណ្តោះអាសន្ន មិនទាន់យល់ គម្ពី ម៉ាក្ស-ឡេនីន បុរូមគ្រូសាស្តចារ្យ បានត្រឹមត្រូវ ពេលណា យៀកណាម បានត្រាស់ដូចអញ ភ្លឺស្វាង ស្មើអញយៀកណាម នឹងស្រឡាំងកាំង ព្រោះ កំពូលអាស្រមកុម្មុយនិស្តពិភពលោក ឈប់នៅឯមូស្គូ ឬ បេកាំង ទៀតហើយ គឺនៅឯក្រុងភ្នំពេញ «កម្ពុជាធិបតេយ្យ»។

ដោយលិចលង់ ក្នុងភាពសុបិន វង្វេងផ្លូវ បែកឆ្វេង នេះហើយ ដែល បន ប៉ុល ពត អៀង សារី សុន សេន នួន ជា អាម៉ុក និង ក្រុមបក្ខវា មើលឃើញ សង្គមជាតិឃើញ ព្រះពុទ្ធបដិមារករណ៏ ឃើញសង្ឃកាតូលិក អ៊ីស្លាម វត្ត វិហារ ម៉ុស្គេ វាកាប់សម្លាប់កំទេច ដុតបំផ្លាញ ព្រោះជាតួយ៉ាង នៃមហាធិរាជ្យ ប្រទាញប្រទង់ វាអោយនៅ ជា បថុចជន សំរេច អរហត្ត មិនបាន។

ចំណែក មូលធននិយម ដែលជា ដំណាក់ការមួយជាន់ខ្ពស់ នៃចក្រពត្រនិយម ឬ សង្គមចក្រពត្រ បែបសហភាពសូវៀត អ៊ឺរ៉ុបខាងលិច ខាងកើត និង សហរដ្ឋអាមេរិក ប្រទេសឧស្សាហ:កម្ម ជឿនលឿន បច្ចេកទេសទំនើប វាសនាប្រទេសទាំងនេះ វាមិនខុសពីភ្នំពេញ ពីព្រៃនគរ (ស៊ៃង៉ុង) ទេ ព្រោះប្រទេសទាំងនេះ នៅលើ ពិភពផែនដី ទាំងអស់ វីឯអញ កម្ពុជាប្រជាធិបតេយ្យ ចិនប្រជាមានិត និង តទីយ:លោក ឯទៀត ជាមហាជនបទ រលំរលាយម្ចាស់ភោគទ្រព្យធម្មជាតិ វត្ថុធាតុដើម ម្ចាស់ព្រៃព្រឹក្ស ក្តាប់ភោគផល់កសិកម្មនេសាទ ។ល។

ថ្ងៃណាសង្រ្គាមលោកទី៣ ផ្ទុះប្រកដ ជាទីក្រុង រលំរលាយ ដូចករណីយ ភ្នំពេញ និង ព្រៃនគរ ឯចឹងហើយ អញអ្នកជនបទ អញប្រាកដជា ជោគជ័យទៀត បុព្វហេតុ ដដែល ម្តេចឡើយ ក៏មិនទទួលផលដដែល ?

គំនិតចៅចាក់សម្អកនេះហើយ ដែលខ្មែរក្រហម មានទំនាស់ ជាមួយខ្មែរយៀកម៉ិញក្រោម ដំបូលផ្ទះរួម នៃកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីជំរុះ ពួកសាធារណ:រដ្ឋនិយម ស៊ីហនុនិយម ប្រជាពលរដ្ឋខ្មែរ ជាង៧លាន ដែលបត់បែនតាមគេ មិទាន់ គេចាប់ផ្តើម ជំរុះបញ្ជី រវាងបងប្អូនសិស្សរួម គ្រូរ របស់គេ ម្តងម្ខាងខ្មែរក្រហម ប្រទាញទៅខាង មាគ៌ា បដិវត្តន៏ «មហាលោតផ្លោះ...» បែបវប្បធម៌គំរូចិនប្រជាមានិត ម្ខាងទៀត ខ្មែរយៀកម៉ិញ ប្រទង់ទៅមាគ៌ា បដិវត្តន៏មួយទៀត បញ្ចូល កម្ពុជា ក្នុងទ្រុងសហព័ន្ធឥណ្ឌូចិន មាន យៀកណាម ជាមេក្លោង ព្រមទាំង សហភាពសូវៀត គាំទ្រពីក្រោយខ្នង។

ការវិវាទគ្នា រវាងបងប្អូនបដិវត្តន៏នឹងគ្នានេះ បង្ហូរឈាមគ្នា៣ឆ្នាំ រហូត អន្តរាគមន៏ ទ័ព ឈ្លានពានយៀកណាមសង្គមនិយម ចូលមករុករាន កម្ពុជា គគ្រឹកគគ្រេង និងតាំងទីនៅក្តាប់កម្ពុជា ក្នុងដែបន្តុប រដ្ឋអំណាចអាយ៉ង «សាធារណរដ្ឋ ប្រជាមានិតកម្ពុជា» រហូតមកដល់សព្វថ្ងៃ។

មតិបងប្អូនខ្មែរ អ្នកវិភាគនយោបាយ សន្និដ្ឋានថា ដូច្នេះដូច្នោះ ភាគច្រើន ខ្មែរអ្នកជាតិនិយម បញ្ចេញយោបលថា ខ្មែរក្រហម ភាគី កម្ពុជាប្រជាធិបតេយ្យ បានបង្ករហេតុ លើកទ័ព ទៅរិករានយៀកណាម ក្នុងគោលដៅ ទាមទារ យកដីកម្ពុជាក្រោម បណ្តាលអោយយៀកណាម ការពារខ្លួន លើកទ័ព មកវាយ កម្ពុជាវិញ ខ្លះទៀតនិយាយថា វត្តមាន «កម្ពុជាប្រជាធិបតេយ្យ» ក្នុងឋានៈជាទ័ពតរស៊ូ នៅជាយដែនកម្ពុជាថៃ គឺផ្តល់លេសអោយយៀកណាម ក្រាញត្រាំត្រៃ ក្នុងដែនដី កម្ពុជា គ្មានថ្ងៃចប់។

អ្នកនេះអ្នកនោះ ចេះតែគ្រលៀងអណ្តាតឈើ តាមចិត្តនឹងឃើញ បំភ្លេចករណីនៅលាវ មានខ្មែរក្រហមឯណា បានជា យៀកណាម បញ្ជូន ទៅក្តាប់ ប្រទេសនោះដែរ ?

នៅអាហ្វក្ខានិស្តង់មាន «កម្ពុជាប្រជាធិបតេយ្យ» ឯណាទៅឈ្លានពាន បានជាសូវៀត លើកទ័ព ទៅឈ្លានពាន អាហ្វក្ខានិស្តង់ ក្នុងដំណាលគ្នានឹង យៀកណាម លុកលុយកម្ពុជា ?

បើពិនិត្យមើលហេតុការណ៏កន្លងទៅ កាលសង្រ្គាមឥណ្ឌូចិន កន្លងទៅ កាលសង្រ្គាមឥណ្ឌូចិនទី១ ឆ្នាំ ១៩៤៦-៥៤ សង្រ្គាមឥណ្ឌូចិនទី២ ឬ សង្រ្គាមយៀកណាម ឆ្នាំ ១៩៥៥-៧៥ កាលសហភាពសូវៀត និង ចិនប្រជាមានិត នៅស្រុះដៃគ្នា ជួយគាំទ្រ យៀកណាម ច្បាំង ទល់នឹងបារាំង្ស ទល់នឹង អាមេរិកាំង កុម្មុយនិស្តនៅកម្ពុជា ទាំងខ្មែរយៀកម៉ិញសិស្សយៀកម៉ិញ មាន ស៊ុន-ង៉ុកម៉ិញ អាចារ្យ ស៊ីវ-ហេង ទូ-សាមុត ជាដើម ខ្មែរក្រហមសិស្សប៉

ក្ខកុម្មុយនិស្តបារាំងផង សិស្សចិនប្រជាមានិតផង មាន ជូន-មុម អៀង-សារី ប៉ុល-ពត ស៊ាន-អាន ជី-គិមអាន កែវ មាស ជាដើម ព្រមទាំង៣៤នាក់ទៀត ជាអតិកៈបក្ខកុម្មុយនិស្តថៃ រួមបញ្ចូលគ្នា ក្នុងឆ្នាំ ១៩៥១ ក្នុង បដិវត្តន៍ ប្រជាជន កម្ពុជា សញ្ញារូប នង្គាល់បក្ខនេះ រំលាយចោល នៅឆ្នាំ ១៩៦២ បាត់ឈ្មោះ ទូ-សាមុត។

ឆ្នាំ១៩៦៣ បក្ខមួយទៀត ឈ្មោះ «បក្ខ កម្មករណ៍ កសិករណ៍» មាន សាឡូត-សរ (ប៉ុលពត) ជា លេខាធិការ បើកសមាជ ជាលើកទី២ បន្ទាប់មក ខៀវ-សំផន ហ៊ូ-យួន ហុយ នឹម ទាំង សាឡូតសរ ទាំង អៀង សារី ចូលព្រៃ។

ឆ្នាំ១៩៦៦ បក្ខកម្មករណ៍កសិករណ៍ ដូរឈ្មោះជា «បក្ខ កុម្មុយនិស្ត កម្ពុជា» ម៉ៅនិយម ដាច់ពី «បក្ខកុម្មុយនិស្ត ឥណ្ឌូចិន» របស់ ហូ ជីមុិញ។

បក្ខកុម្មុយនិស្តឥណ្ឌូចិននេះ ក៏បាន រំលាយចោលដែរ ប្រហែលជា មានទាស់និស័យ ជាមួយកម្ពុជាផង ជាមួយយៀកណាមខាងត្បូងផង ជាមួយលាវផង តែរំលាយរូបភាព ដូចម្តេចក្តី រច្ចនាសម្ព័ន្ធ និង គោលដៅ ក្តោបក្តាប់ ឥណ្ឌូចិន ជា «សហព័ន្ធឥណ្ឌូចិន» នៅតែដដែល ជាដរាប។

សរអោយឃើញថា កាលសហភាពសូវៀត ចិនប្រជាមានិត យៀកណាម មានប្រយោជន៍ រួមក្នុងកិច្ចកំចាត់ចក្រពត្រអាមេរិកាំង និង បនប្រតិកិរិយា សីហនុ លន់ នល់ ង៉ោ ឌីញ យៀម ធីវ និង គី ព្រមទាំង សុវណ្ណភូម៉ា ភូមីណូសវណ្ណ ខ្មែរយៀកមុិញ និង ខ្មែរក្រហម ក៏ ឯកភាពល្អ កល្អើន ជាមួយគ្នា ល្អណាស់ ទោះស្រាំក្នុងចិត្ត យ៉ាងណាក៏ដោយ។

សង្គ្រាមឥណ្ឌូចិនទី២ចប់ អាមេរិកាំងដកខ្លួនចេញពី យៀកណាម ដែនដី អតីតៈ ឥណ្ឌូចិនបារាំង កម្ពុជា យៀកណាម លាវ ក្រឡាប់ទាំងដុល ចូលក្នុងចង្កូម កុម្មុយនិស្ត។ សហភាពសូវៀត ចិនប្រជាមានិត មានទំនាស់នឹងគ្នា អំពីរឿង ក្តាប់អំណាច លើប្រទេស កុម្មុយនិស្តទូទៅទាំងអស់លើពិភពលោក បន្ទាប់ពី មរណៈភាព នៃលោក ស្តាលីន រវាង លោក គ្រុតឆែវ និង ម៉ៅ ឆេទុង អំពីវិប័ត្តព្រំដែនភាគខាងជើង ឆៀងខាងកើត ក្បែរ កូរ៉េខាងជើង និង ភាគខាងលិច ព្រមទាំង បញ្ហាអណិកជន ជាតិកាស៊ាក្ខក៏ និង អុយ ក្គួរ ក្នុងខេត្ត ហ្ស៊ីងចាង បញ្ហាផ្ទៃដីជាង ១លានកន្លះគ.ម$^{2}$ ដែលចិនប្រជាមានិត ទាមទារ ពីសហភាពសូវៀត មានការប៉ះទង្គិចគ្នា បង្ហូរឈាមគ្នា ទៅវិញទៅមកផ្តុំទ័ព រាល់លាន ឈមមុខទល់គ្នា តាមខ្សែព្រំដែន ប្រវែង ៥.០០០គ.ម. រកាំរកូស តាំងពីឆ្នាំ ១៩៦០ មក។

ជាមួយយៀកណាម ប្រវត្តិសាស្ត្រ ចង្អុលបង្ហាញថា មហាប្រទេសចិន ទោះបីជា ប្រជាមានិត ក៏ដោយ ផែនការ លោក ស៊ីន យ៉ាត់សេង ដែល កុម្មុយនិស្តចិន លើកជា វិរៈបុរស ក៏ គ្រោង បញ្ចូល រដ្ឋអាណ្ណាម ក្នុងដែនដីរបស់ចិនដែរ។ យៀកណាម ជា ប្រទេស តែមួយនៅ

ជ្រោយសុវណ្ណភូម៌ និង អាស៊ីភាគអគ្នេយ៍ ដែលទទួល ឥទ្ធពល វប្បធម៌ អរិយ:ធម៌ របៀបរបបរច្ចនាសម្ពន្ធផ្នែក សង្គមរដ្ឋបាល យោធាចិន។ កុងហ្វូជឺ ទស្សនៈវិទ្ទូចិន ដំណាលគ្នានឹងពុទ្ធកាលជាប្រភព នៃសតិអារម្មណ៍ ស្នាតីជនជាតិយៀកណាម។ ជនជាតិយៀកណាមខ្លួនឯង ជាអណិកជន មានកំណើតដើម នៅ ខេត្តចិន ភាគខាងត្បូង ចាប់តាំងពីរជ្ជកាលលី សម័យ ដាយវៀត ដើមសត្តវត្សទី១១។ ប្រវត្តិសាស្ត្រយៀកណាម ជាប្រវត្តិសាស្ត្រសង្គ្រាម ក៏សាងឯករាជ្យ ទល់នឹង មហាប្រទេសចិន មាន វិរ:បុរស លី ធឿងគាត និង ហ៊ុង ដាវ ធ្លាប់កំទេចទ័ពចិនជំនាន់ម៉ុងគ្នោល នៅញូញឹក និង បាចដាង កាលពីសត្តវត្សទី១៣ រជ្ជកាល ព្រះជ័យវរម្ម័នទី៧ សម័យមហានគរ នៅស្រុកខ្មែរ។ ឥរិយាបទ យៀកណាម ដែលយៀកណាម ផ្តាប់វាសនាខ្លួន ជាមួយ សហភាពសូវៀត បន្ទាប់ពី អាមេរិកាំង ដកទ័ព មានពន្លឺសមហេតុផលក្នុងបរិយាកាសនេះ។ ដូច្នេះ មូលដ្ឋានយោធាសូវៀត អាកាសចរណ៍ នាវាចរណ៍ នៅ កាំរ៉ាញ់ ដាណាង និង ការប្រើប្រាស់កំពង់ផែហាយហ្វុងក្តី កំពង់សោមក្តី ជាជញ្ជីងលំនឹង របស់យៀកណាម ទប់នឹងទម្ងន់ ប្រវត្តិសាស្ត្រយៀកណាម ជាមួយចិន ផ្នែក ភូមិយុទ្ធសាស្ត្រ។

អំពី «កម្ពុជាប្រជាធិបតេយ្យ» វិញប្រវត្តិសាស្ត្រ ជាមួយ យៀកណាម ក៏ដូចគ្នានឹង យៀកណាម ជាមួយចិនដែរ។ អ្នកនិពន្ធយៀកណាមម្នាក់ ឈ្មោះ ឡៃ ថាញ់ខើយ រជ្ជកាល រាជវង្សង្វៀង កាលដើម សត្តវត្សទី១៦ សម័យក្រុងលង្វែក នៅស្រុកខ្មែរ បាននិពន្ធសាត្រាមួយ មានចំណងជើងថា «កិច្ចវាតទី ទម្លាយ រកដីថ្មី» ភាសាយៀកណាមថា «ណាមទៀន» បំផុសសម្បជញ្ញៈជនជាតិ យៀកណាមថា យៀកណាម ដើម្បីរស់លូតលាស់ទៅបាន អាស្រ័យនឹង ប្រទេសយៀកណាម រីកទូលំទូលាយជា «មហារដ្ឋយៀកណាម» ភូមិសាស្ត្រ ចំនួនប្រជាជន ព្រមទាំង ការកៀបសង្កត់ របស់ចិន ពីទិសខាងជើង តម្រូវអោយ ពង្រិកដែនដី ចុះមកភាគខាងត្បូង បែបដូចគ្នា នឹងទ្រឹស្តី «ទំហ៊ុំដែនដីអាយុជិវិត» នង្គាល់ចិញ្ចឹមដាវ ដាវចិញ្ចឹមនង្គាល់ ឬ ន័យប្រហាក់ប្រហែលនឹង ពាក្យខ្មែរ ខ្លារក្សាព្រៃ ព្រៃរក្សាខ្លាឬ ប្រហាក់ប្រហែលនឹងពាក្យចិន ទឹកមានត្រី ត្រីរស់នៅក្នុងទឹក។

រាជវង្ស ង្វៀង បានអនុវតន៏កម្ពី របស់ អ្នកនិពន្ធនេះ រំលំប្លន់ វិបយក ចម្ប៉ាបូរី បញ្ចូលក្នុងរដ្ឋយៀកណាម ហើយចេះតែ បន្តដំណើរ មកទឹសខាងត្បូងទៀត តំរង់ មកកម្ពុជាក្រោមទទួលពេលនោះ ក្រុងឧត្តុង្គ ប្រទេសកម្ពុជា ទើបនឹង ស្ថាបនាថ្មី បន្ទាប់ពីការរលំនៃបន្ទាយលង្វែក (ឆ្នាំ១៥៩៤) ព្រះស្រីសុរិយោព័ណ បាន ព្រះចៅសៀម ដង្ហែរមក បន្តុបគ្រងរាជ្យ នៅក្រុងថ្មីនេះ ព្រះអង្គទ្រង់ ព្រះតំរិះ ចង់រលាស់ខ្លួន អោយផុត ពីការរួបរឹតរបស់ ព្រះចៅសៀម ដែលចាត់ទុក ក្រុងកម្ពុជា ជាប្រទេសរណប បែបបទ រដ្ឋបាលជីវភាពរស់ នៅក្នុងវាំង ជាសៀម ទាំងអស់ ព្រះអង្គ ក៏ឈ្វេងយល់ថា ត្រូវចងស្ពានមេត្រីជាមួយ ព្រះចៅក្រុងអាណ្ណាម (ក្រុងវ៉ែ )តាមរយ:អពារពិពារ រវាង ព្រះរាជបុត្រ មហាឧប្ប

រាជ ដែលជា អ្នកស្នងរាជតំណរពីព្រះអង្គព្រះ នាមព្រះជ័យជេដ្ឋាទី២ ជាមួយព្រះក្សត្រីក្រុងវ៉េ ព្រះនាមកូជីន(បុត្រីទី៩)។

ក្នុងរាជព្រះជ័យជេដ្ឋាទី២នេះហើយ ដែលយៀកណាមប្តើមមករាតទី ដល់ដីព្រៃនគរផ្លាសជា សេក្ខងក្នុងសម័យអាណានិគមបារាំង ឥឡូវនេះជា ក្រុង ហូជីមិញ ព្រមទាំង រាតដល់ខេត្តឯទៀតជុំវិញក្រុងព្រៃនគរ ទទួលបន្ទាប់មកទៀត យៀកណាម ជួបឧប្បស័គ្គមានសង្គ្រាមក្នុងស្រុក១០០ឆ្នាំ ដំណើរមកទីសខាងត្បូង ក៏ខ្សោយសន្ទុះ រហូតដល់បារាំង ទៅដល់ ក្តោប កម្ពុជាក្រោម ដាក់ជាអាណានិគមបារាំង ប្លែកពី អាណ្ណាម តុងកឹង (យៀកណាម ខាងជើង) កម្ពុជា និង លាវ មានល័ក្ខន្តិកៈ ជាអាណាព្យាបាល។

ហូ ជីមិញ បន្តនយោបាយរាតទីនេះ បញ្ចូលក្នុងគំរោងនិវេទន៍ប័ក្ខកុម្មុយនិស្តឥណ្ឌូចិនក្នុងឆ្នាំ១៩៣០ ក្តោបប្រមូល ទាំងកម្ពុជាក្រោម (យៀកណាមខាងត្បូង)ទាំងកម្ពុជា កណ្តាល ទាំងលាវក្នុង «សហព័ន្ធឥណ្ឌូចិន» រូបភាពលក្ខណៈសម្បត្តិ ដូចគ្នាបេះបិត «មហារដ្ឋយៀកណាម» របស់ ព្រះចៅអធិរាជក្រុងវ៉េ។

ដោយកត្តាទាំងអស់នេះហើយ ដែលខ្មែរក្រហម បក្ខកុម្មុយនិស្តកម្ពុជា ព្រមទាំង សម្តេចសីហនុ ជ្រើសចិនប្រជាមានិត ជាសម័ន្ធមិត្ត។ ទំនាក់ទំនងមិត្តភាព រវាង ចិន និង កម្ពុជា តាំងពីសម័យនគរភ្នំ (ហ្វូណន់) ចេនឡា មហានគរ មក ក៏ មិនដែលមាន រអោយថានទឹងគ្នាដែរ។ ម្យ៉ាងទៀតនយោបាយចិនប្រជាមានិត ជំទាស់ដាច់ខាតនឹង «សហព័ន្ធឥណ្ឌូចិន» របស់ យៀកណាម មានតែសូវៀតទេ ដែលគាំទ្រ នយោបាយនេះ ព្រោះសូវៀតត្រូវការដែនដីនេះ តាំងមូលដ្ឋាន បែរមុខឆ្ពោះ ទៅកំញើញចិន នៅទិសខាងជើង ក្តាប់បានភាគខាងត្បូង នៃមហាសមុទ្រប៉ាស៊ីហ្វិក ទល់នឹងមូលដ្ឋានសហរដ្ឋសហរដ្ឋអាមេរិកនៅកោះគួម ស៊ុយបិក បេយ៍ក្លារ កហ្វែលដ៏ ក្នុងផ្ទៃសមុទ្រប្រទេសហ្វីល្លីព្ពិន ព្រមទាំងលយក្តោងច្រមុះ ទៅរក មហាសមុទ្រឥណ្ឌៀ។ ចិនប្រជាមានិត មានប្រយោជន៍ ក្នុងចំណុចដែលគ្រប់ប្រទេស ក្នុងតំបន់អាស៊ីអគ្នេយ៍(សុវណ្ណភូមិ) ជាពិសេសប្រទេសអតិតៈដែនដីឥណ្ឌូចិនបារាំង ថិតនៅជា ប្រទេសឯករាជ្យដាច់ទទៃៗផ្សេងៗពីគ្នា បែប ចង្កោមប្រទេសជួរភ្នំបាល់កង់ យូគ្រោស្លាវី អាល់បានី ប៉ូលក្ការី រូម៉ាណី។

កម្ពុជាប្រជាធិបតេយ្យ ភាគីខ្មែរក្រហម មានសំរើបចិត្ត ចង់បានដូច្នេះឯង តែជាអកុសល់ មាន យៀកណាម សហភាពសូវៀត និង បាវព្រាវ «សាធារណៈរដ្ឋប្រជាមានិតកម្ពុជា» ជាឧបស័គ្គ។ សង្គ្រាមនៅកម្ពុជា រវាង «កម្ពុជាជាប្រជាធិបតេយ្យ» មាន ចិនប្រជាមានិតជាបង្អែក ទល់នឹង យៀកណាមសង្គមនិយម មាន «សាធារណៈរដ្ឋប្រជាមានិតកម្ពុជា» ជាអ្នកស្តាយគ្រាប់ និង ស្បៀងជួស និង សហភាពសូវៀត ជាបង្អែក គឺថិតនៅបរិយាកាសនេះ ខាងណាឈ្នះ ក៏ កម្ពុជា នៅតែ កុម្មុយនិស្ត ដដែល មិនមែនជា សង្គ្រាម

រំដោះក្នុងគោលដៅមួយ ដែលនាំ កម្ពុជា អោយក្លាយជា ប្រទេសសេរី ក្នុងអនាគត សង្គមខ្មែរអ្នកជា បែបរាជាណាចក្រថៃ ម៉ាឡេស៊ី ប្រ៊ូណេយ៍ ឬ បែប សាធារណៈរដ្ឋសឹង្ហបូរី ឥណ្ឌូណេស៊ី ហ្វីល្លីពីន ទេ។

រាជានិយម របស់ ស្តេច សីហនុ ឬ សាធារណៈរដ្ឋនិយម របស់ លោក ស៊ីន សាន គ្មានរាជបល្ល័ង្គ គ្មានកៅអី កន្លែងអង្គុយ ក្នុង «កម្ពុជាប្រជាធិបតេយ្យ» និង ក្នុង »សាធារណៈរដ្ឋប្រជាមានិតកម្ពុជា» ទាល់តែសោះ! សំខាន់បំផុត ខ្មែរអ្នកជាតិនិយម ខ្មែរអ្នកស្រឡាញ់ឯករាជ្យ ប្រជាធិបតេយ្យសេរី ពិតប្រាកដ សិទ្ធក្នុងការសំរេច វាសនាខ្លួន ដោយ ខ្លួនឯង ត្រូវតែមាន សម្បជញ្ញៈថា គ្មានឯករាជភាព ក្នុងកុម្មុយនិស្ត ទោះចិនក្តី ទោះយៀកណាមក្តី គ្មាន ប្រជាធិបតេយ្យភាព ពិតប្រាកដ ក្នុង «កម្ពុជាប្រជាធិបតេយ្យ» គ្មានអធិបតេយ្យភាព សំរាប់ប្រជាជន ក្នុង «សាធារណៈរដ្ឋប្រជាមានិតកម្ពុជា» ព្រោះ រដ្ឋនេះ សាធារ សំរាប់តែចែកចាយ ឲតែ ប្រជាជនយួន តែខ្មែរ គ្មានសេរីភាព ជា ខ្មែរអ្នកជាទេ។

## យុទ្ធសាស្ត្រ សម្តេច សីហនុ



### តើមាគ៌ាឯណា ដែលខ្មែរ អាចរំដោះខ្លួនបាន ?

សម្តេច សីហនុ ព្រះអង្គបាន ត្រួសត្រាយផ្លូវ៤ យ៉ាងហើយ មានជំនឿ ទៅលើខ្លួនព្រះអង្គ ថា ជាមាគ៌ាដែលត្រូវតែធ្វើ៖

**១**.តាមរយៈប្រទេសជាមិត្ត មានសហរដ្ឋអាមេរិក ចិនប្រជាមានិត បារាំង ជប៉ុន និង សមាគម ប្រទេសអាស៊ី (អាស៊ាន) ដូច សឹង្ហបូរី ជាដើម ស្រុះគ្នា គាំទ្រព្រះអង្គ ពង្រីក និង ពង្រឹងទ័ពជាតិសីហនុនិយម ដំឡើង យ៉ាងតិចបំផុត ត្រឹម ៥០.០០០នាក់ ប្រដាប់ដោយ សម្ភារៈ និង អាវុធទំនើប យកទៅច្បាំង ដេញ ទ័ពឈ្លានពានយៀកណាម។ នយោបាយ ផ្សះផ្សាជាតិ រវាងភាគីទាំង៤ ត្រូវទុកជាចរមានដដែល កងទ័ពអន្តរជាតិ ធានាសន្តិភាព ក៏ត្រូវតែងតាំង និង ដាក់ប្រចាំការណ៏ជាអចិន្ត្រៃនៅ កម្ពុជា បង្ការរដ្ឋប្រហារ ពីសំណាក់ភាគី «កម្ពុជាប្រជាធិបតេយ្យ» និង «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ កងទ័ពជាតិសីហនុនិយម ហុចលទ្ធភាព អោយប្រជាពលរដ្ឋខ្មែរ មានការកក់ក្តៅ មានសេចក្តីសង្ឃឹម មិនតាំងនៅចន្លោះ តែខ្មែរក្រហម និង ខ្មែរយៀកម៉ិញ មួយស្លាប់ដោយតៃហោង មួយទៀត ស្លាប់ដោយសន្ទឹម។ ឃើញ ទ័ពជាតិសីហនុ ទៅដល់ ប្រជាពលរដ្ឋខ្មែរ មុកតែអបអរទទួល...។

**២**.មាន សេចក្តីថ្លែងការណ៏រួម រវាង លោក **ង្វៀង កូថាច់** និង បណ្ឌិត **កុសុ ម៉ាដ្សា** រដ្ឋមន្ត្រីក្រសួងការបរទេសយៀកណាម និង ឥណ្ឌូណេស៊ី ដែលប្រកាស នៅក្រុង ហូជីម៉ិញ នៅឆ្នាំ១៩៨៧ មកធ្វើជាមូលដ្ឋាន។

ដំណាក់ការណ៏ទី១៖ កោះប្រជុំសន្និសិទ ចតុភាគីរវាង **រ.រ.ជ.ក.ឯ.អ.ស**. របស់ សម្តេច សីហនុ **រ.ជ.រ.ប.ខ**. របស់ លោក ស៊ឺន សាន **ក.ប**. របស់ លោក ខៀវ សំផន និង **ស.ប.ម.ក** .របស់ លោក ហេង សំរិន ដោះស្រាយរក អោយបាន ការសំរ៉ុះសំរួលផ្សះផ្សាជាតិមួយ បង្កើតជា «រដ្ឋាភិបាលបណ្តោះអាសន្ន ចតុភាគី»។

ដំណាក់ការណ៍ទី២៖ តែងតាំងបានរដ្ឋាភិបាលនេះហើយ ភាគតីទាំង៤ ត្រូវចរចា ជាមួយ យៀកណាម អំពីបញ្ហាដកទ័ពយៀកណាមចេញពីកម្ពុជា។ រីឯ កងទ័ពជាតិ រួមជាកង ទ័ពជាតិចតុភាគី។

**៣**.មាន លោកប្រធាន **យែស្សឺរ៍ អារ៉ាហ្វាត** នៃចលនារំដោះជាតិ ប៉ាឡេស្ទីន ជា បង្គោល ព្រមទាំងប្រទេស ដែលមិនចូលរួមក្នុងប័ក្ខសម្ព័ន្ធខាងណាមួយចំនួន ដែលគាំទ្ររូបមន្ត របស់ព្រះអង្គ៖

ក) រំលាយចោលនៃរដ្ឋអំណាច «សាធារណរដ្ឋប្រជាមានិតកម្ពុជា» ដំឡើងរដ្ឋថ្មីមួយទៀត ជា រដ្ឋ មិនកុម្មុយនិស្ត មិនរួមក្នុង ប័ក្ខសម្ព័ន្ធខាងណា របបពហុប័ក្ខ មានទាំង ប័ក្ខកុម្មុយនិស្ត ក្នុងនោះផង។ ដំបូងបើគ្មានភាគីឯទៀត ត្រូវរ៉ូវគ្នា មានតែទ្វេភាគី «**ហ្វុនសាំងប៉ិច**» និង «ប័ក្ខប្រជាជនកម្ពុជា» ត្រូវរ៉ូវគ្នាបណ្តើរៗសិនទៅ បន្ទាប់មកទៀត ជាត្រី និង ចតុភាគី។

ខ) តែងតាំង រដ្ឋាភិបាល បណ្តោះអាសន្ន កម្ពុជា តាម សមាសភាពខាងលើ។

គ) លោក **យែស្សឺរ៍អារ៉ាហ្វាត** ផ្ញើបញ្ជី រាយនាម ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ដែលស្មោះស្មាក់ ចង់ជួយជ្រោមជ្រែងព្រះអង្គ តាមរូបមន្តនេះ ដើម្បី ព្រះអង្គ នឹងអំពាវនាវ សុំអោយ គេបើកសកម្មភាព ដោយអញ្ជើញ លោក ហេង សំរិន ហ៊ុន សែន ខៀវ សំផន និង ស៊ីនសាន មកអង្គុយជុំវិញតុមូលមួយ ពីគ្រោះ ដោះស្រាយ ចំណុចពីរប្រការ មានរឿងរំលាយ រដ្ឋ «សាធារណរដ្ឋប្រជាមានិតកម្ពុជា» និង ការបោះពន្លាជ័យ នៃកងទ័ពអន្តរជាតិ ធានា សន្តិភាព ជំនួស ទ័ពយៀកណាម ដែលត្រូវ ដកចេញ។

ក្នុងករណីយ៍ណា ដែលភាគីខ្មែរក្រហម និង លោក ស៊ីន សាន នៅរឹងរូស មិនព្រម ចូល រួម ជាមួយរដ្ឋាភិបាលទ្វេភាគី (សីហនុ និង ហេង សំរិន) នៅតែត្រូវបង្កើតឡើងជានិច្ច ហើយចេះតែ អំពាវនាវបន្ត ហៅរកបងប្អូន បើគេនៅតែ បដិសេដ្ឋ ដាច់អហំការ ធ្វើសង្គ្រាមទល់ទ្វេភាគី ពេលនោះជៀសមិនផុត ពីមានសង្គ្រាមស៊ីវិល ក្នុងស្រុក។ តែសម្តេច សីហនុ ទ្រង់ មានជំនឿថា ចិនប្រជាមានិត និង ថៃឡង្គ មានប្រាជ្ញា ឆ្លាតប្រាកដ មិនបណ្តោយ អោយធ្លាក់ ក្នុងសភាពការណ៍ បែបនោះទេ។

មួយវិញទៀត នៅក្នុងរដ្ឋមួយ ដែលលគ្មាន កងទ័ព ឈ្លានពាន យៀកណាម តាំងនៅ ច្បាស់ជាមាន ប្រទេសជាមិត្ត គាំទ្រ ចងស្ពានមេត្រី សន្ទឹកសន្ទាប់ ភាគីខ្មែរក្រហម និង **រណះសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ** (ភាគីស៊ីនសាន) គ្មានបុព្វហេតុអ្វី នឹងបន្តសង្គ្រាមទៀត ទេ។

**៤**.កងទ័ពបដិវត្តន៏ បែប **នីការ៉ាគ្វា** ផ្គត់ផ្គង់ ដោយ **ស៊ី.អៃ.អា.** អាមេរិកាំង សម្តេចបន្ត សំណេរបស់ព្រះអង្គ អះអាងថា

*«នៅតាមជុំរុំខ្មែរភៀសខ្លួន ក្នុងប្រទេសថៃ មានយុវជនខ្មែរជាច្រើន រង់ចាំតែមធ្យោបាយសម្ភារៈ និង ហិរ័ញ្ញឹក នឹងមានឳកាស ផ្លៀតបំពេញភារៈខ្លួន ចេញវាយអាខ្មាំងយួន។ ទ័ពស៊ីឈ្មួលចៀំង និង ស៊ីអៃអេ ក៏នៅទំនេរសន្ទឹកសន្ទាប់អាចបង្កើតជាកងទ័ពខ្លាំងបានព្រះ អង្គបង្ហើយអោយដឹងថា អាមេរិកាំង បានទាក់ទងជាមួយព្រះអង្គខ្លះដែរទៅហើយ តែខកខានទៅវិញដោយសារអាមេរិកាំង គេមិនសូវចូលចិត្តព្រះអង្គស្ពាយដែរ បើប្រសិន ជាទ័ពនេះផុសចេញបាន កម្ពុជា នឹងអាចរំដោះខ្លួនបាន»*

អត្ថាធិប្បាយលើសេចក្តីអះអាងរបស់សម្តេចស៊ីហនុនេះ៖ *អាមេរិកកាំងមិនចូលចិត្ត សីហនុ ពីព្រោះក្រោយ ពីបានស្តាប់វិធីសាស្ត្រ របស់ សម្តេច សីហនុ អាមេរីកាំង មើលឃើញភ្លាមថា សម្តេច សីហនុ មិនអាចចេញរួចពីទ្រុងកុម្មុយនិស្តចិនបាននោះទេ ព្រះអង្គ នៅតែមានជំនឿលើចិនជានិច្ច ថាជា ព្រះបាទធម្មឹកខ្មែរ។ ដូច្នេះ អាមេរិកាំង ឈប់យកសីហនុជាមនុស្សបានការ ក្នុងដំណោះស្រាយខ្មែរ អោយខ្មែរ ចេញរួចពីនឹមកុម្មុយនិស្ត។*

លើកយកដំណោះស្រាយទាំង៤ របស់ សម្តេច សីហនុ ដែលបានរៀបរាប់ដោយសង្ខេបនេះ មកវិភាគ ឃើញមានចំណុចជាច្រើន ដែលប្រកប ដោយសុភវិនិច្ឆយ ចំណុចខ្លះទៀត មិនមានរូបភាព ជាប្រាកដនិយមទេ។

**ចំណុច សុភៈវិច្ឆ័យ**

១. គំនូសរូបភាព អានាគត កម្ពុជា ប្រាសចាក របបកុម្មុយនិស្ត ជា កម្ពុជាសភានិយម ពហុបក្ខ នយោបាយអព្យាក្រឹត អត់ចូលរួមបក្ខសម្ព័នខាងណា។

២. មាននយោបាយ សំរ៉ុះសំរួល ផ្សះផ្សាជាតិ គ្រប់ភាគីខ្មែរ ដែលសំដែងតួលើឆាកនយោបាយ។

៣. តវិយាបទស្របនឹងឆន្ទៈប្រជាពលរដ្ឋ។

**ចំណុចមិនប្រាកដនិយម**

១. ផ្នែក នយោបាយរដ្ឋាភិបាល បណ្តោះអាសន្ន កម្ពុជា អាចជា ចតុភាគី បន្ទាប់ពីបោះឆ្នោត ជ្រើសរើស ប្រមុខរដ្ឋ ឬ សភាជាតិ។ គណបក្ស ណាឈ្នះឆ្នោត មេគណបក្សនោះ ត្រូវ

ទទួលដំណែងជាប្រមុខរដ្ឋ គ្រប់គ្រងរដ្ឋ ទៅតាមច្បាប់រដ្ឋ ដែលបានអនុមតិ ជាភាគច្រើន ពីសភាជាតិ។ បើប័ក្ខ មានធាតុជាកុម្មុយនិស្ត ឈ្មោះ (ខ្មែរក្រហម ឬ ខ្មែរយៀកម៉ិញ ឬ អភិគមពួកទាំងពីរ) កុម្មុយនិស្ត មិនដែលទុក អោយមានប័ក្ខជំទាស់ ពាំងពីមុខនោះទេ ពេលនោះ របបប្រជាធិបតេយ្យសេរី នឹងក្លាយ ភាពជាប្រជាធិបតេយ្យ បែបកុម្មុយនិស្ត ហើយកម្ពុជា ក៏នៅតែក្នុងឥទ្ធិពលកុម្មុយនិស្តដដែល។

តែបើពួកកុម្មុយនិស្តចាញ់ឆ្នោត ប័ក្ខ ហ្វុងស៊ិុបិច និង ប័ក្ខ លោក ស៊ីន សាន ពួកកុម្មុយនិស្ត អាចនឹងមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ហើយរកយុទ្ធសាស្ត្រ គ្រប់បែបយ៉ាងដើម្បីការពារអំណាចខ្លួនជានិច្ច។ នេះហើយ ជាគ្រោះថ្នាក់ ដែលអាចកើតមានឡើងក្នុងដំណោះស្រាយនេះ។

២. កងទ័ពជាតិចតុភាគី៖ យើងដឹងថា កងទ័ពជាតិ មាន បេសកម្ម ការពារឯករាជ្យ បូរណភាពទឹកដី ទល់នឹង សត្រូវ ពីក្រៅប្រទេស ព្រមទាំង ធានាសន្តិសុខ របៀបរៀបរយ ទូទៅ ជូនប្រជាពលរដ្ឋ តាមសំណើរ ឬ កំណែ នៃប្រជាជាតិ តាមរយៈ រដ្ឋាភិបាលកងទ័ពជាតិ មានតែ ជាតិ ជាម្ចាស់ កម្មសិទ្ធ មិនត្រូវ ប័ក្ខនយោបាយណាមួយ ជាម្ចាស់ ជាមេបញ្ជាការទេ អ្នកឧប័ត្ថមទ័ពនេះ គឺជាតិ កងទ័ពជាតិ ត្រូវថិតនៅក្នុង ភាពអព្យាក្រឹត មិនលាយឡំ ក្នុងប័ក្ខនយោបាយឡើយ វិស័យ បញ្ជាការដ្ឋានតែមួយ ក្បួនប្រយុទ្ធតែមួយ បើមិនដូច្នោះទេមិនអាចមាន វិន័យបានទេ អានាធិបតេយ្យ បណ្តាលអោយក្លាយជាហ្វូង ឥតសណ្តាប់ធ្នាប់ មិនអាចទទួល បេសកម្ម ធ្វើសង្គ្រាមការពារជាតិបានទេ។

ប័ក្ខ នយោបាយ ក្តាប់បញ្ជាការកងទ័ព កងទ័ពត្រូវតែប្រឡូកជាមួយប័ក្ខ ប័ក្ខនិងប័ក្ខប្រយុទ្ធគ្នា ក្លាយជាសង្គ្រាមស៊ីវិល ក្នុងស្រុក ដូចករណីយ «កម្ពុជាប្រជាធិបតេយ្យ» ក្នុងចន្លោះ ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩។

៣.កងទ័ពអន្តរជាតិធានាសន្តិភាព «International’s Peace Keeping Forces» បើភាគីទាំង៤ តំកល់ទុក ក្នុងកណ្តាប់រៀងៗខ្លួន កងទ័ពអន្តរជាតិ នឹងក្លាយ ជាជាទ័ព «អន្តរទីតាំង» «Forces d’interposition» ដូចគ្នានឹង ទ័ពបារាំង អាមេរិកាំង នៅ ប្រទេស លីបង់។

អសន្តិសុខកើតឡើង ដោយភាគីទាំង៤ ហើយ រដ្ឋាភិបាលចតុភាគីទាំង៤ ខ្លួនឯងពឹងគេអោយធ្វើអន្តរាគមន៍ ប្រៀបបាននឹង មនុស្សឈឺ ដោយបំពុលខ្លួនឯង «**ខ្លួនឯងបំពុលខ្លួនឯងអោយឈឺដើម្បីស្រែករកពេទ្យមកព្យាបាល**»។

ដូច្នេះកងទ័ពភាគីទាំង៤ ត្រូវតែរំលាយចោល ជាមួយគ្នានឹងរដ្ឋ «កម្ពុជាប្រជាធិបតេយ្យ» និង «សាធារណរដ្ឋប្រជាមានិតកម្ពុជា» រំលាយអោយស្អាត អស់រឡីង កងទ័ពជាតិពិតប្រាកដ បើចាំបាច់ អាចបង្កើតជាថ្មីឡើងវិញ ពេលក្រោយរំលាយ ទ័ពភាគី តែបើ

ទុកទ័ពភាគីទាំងអស់នេះ ប្រជាពលរដ្ឋខ្លាចរអារ មិនអាច កក់ក្តៅ មិនមាន សន្តិសុខ ឬ សន្តិភាពបានទេ មិមមែន ទ័ពជាតិ ជាតិមិនអាចទុកចិត្តបានទេ។

៤. សង្គ្រាមនៅកម្ពុជា ជាសង្គ្រាម រវាងកុម្មុយនិស្ត នឹងកុម្មុយនិស្ត។ ថៅកែ ម្ចាស់សង្គ្រាម គឺ ចិនប្រជាមានិត សហភាពសូវៀត និង យៀកណាម សោបិទ បើកខ្យល់ បញ្ចេះ ឬ ពន្លុនសង្គ្រាម នៅក្នុងដៃប្រទេសទាំងបី។ បារព្រោះ «កម្ពុជាប្រជាធិបតេយ្យ» និង «សាធារណរដ្ឋប្រជាមានិតកម្ពុជា» មានស្អី ទៅបិតខ្យល់ ពន្លត់ភ្លើងសង្គ្រាមកម្ពុជាបាន បើនគរទាំងបីនេះ ជាកំពង់បិត បង្ហូរខ្យល់ រំសេវ បំពង់ភ្នក់ភ្លើងសង្គ្រាមខ្លួនឯង ?

ពួកកុម្មុយនិស្ត បើវា ធ្វើសហប្រតិបត្តិការណ៍ ជាមួយគ្នា ជាមួយពួក គហបតី គឺគ្រាន់តែជាល្បិចឆើត ស្របច្បាប់ ចូលមក ប្រហារខ្មាំង ស៊ីរូងផ្ទៃក្នុង ល្បិញនេះជាល្បិញ លួចចាក់សម្លាប់ពីក្រោយខ្នង តែប៉ុណ្ណោះ។ ជាដំបូង វាទុក រដ្ឋអំណាច វណ្ណៈគហបតីអភិជន ឬក្សត្រ ជាឧបករ សំរាប់តែ បង្រាបប្រជាពលរដ្ឋ អោយវា បន្ទាប់មក វាធ្វើអោយមានអភិឃាតគ្នា ដើម្បី វាស្រួល កំចាត់ ម្តងមួយៗ អោយស្លាប់សាបសូន្យ។ ល្បិចខ្មែរក្រហម និង ខ្មែរយៀកម៉ិញ ធ្លាប់អនុវត្ត ជាមួយសង្គមរាស្ត្រនិយម របស់ សម្តេចឪ មានគ្នាវាចូលបង្កប់ខ្លួន ក្នុងសភាជាតិ ក្នុងរាជរដ្ឋាបាល ស៊ីរូងផ្ទៃក្នុង គ្នាវាផ្សេងទៀត បំប៉ះបំបោរ នៅក្នុងព្រៃ បង្ករអសន្តិសុខ ដូចករណីយ ភូមិសំឡូត នៅខេត្តបាត់ដំបង ពីឆ្នាំ ១៩៦៥-១៩៦៦ ដូចករណីយ វាអនុវត្តនៅកម្ពុជា ក្នុងសង្គ្រាម៥ឆ្នាំ (១៩៧០-ល់១៩៧៥) ក្នុងក្របខ័ណ្ឌរណៈសិរ្សរួបរួមជាតិ និង រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា របស់ សម្តេចសីហនុ និង សម្តេច **ប៉ែននុត** ជាតឹកតាងស្រាប់។

កុម្មុយនិស្តត្រូវការ រដ្ឋសីហនុ ដើម្បី ប្រើអំណាចរដ្ឋនេះ ភូតកុហករាស្ត្រថា វាជួយដោះលែងវណ្ណៈអធន អោយទៅជា ទេវតាគ្រប់គ្នា ក្នុងឋានសួគ៏លោកីយមួយ នៃពិភពកុម្មុយនិស្ត។ នេះជាអភិធម៏នៃ «ព្រះបរុមគ្រូសាស្តាចារ្យ» ម៉ាក្ស និង ឡេនិន ដែលពួកខ្មែរក្រហម និង ខ្មែរយៀកម៉ិញ យកមក អនុវត្ត នៅស្រុកខ្មែរ។ ប្រជាពលរដ្ឋខ្មែរ បានស្គាល់ល្បិចដ៏ថោកទាប និង សាហាវព្រៃផ្សៃនេះ ទាំងអស់គ្នា ធ្លាប់ជួបប្រទះ អំពើ ដែលកុម្មុយនិស្តលួចប្លន់ រិបយកសម្បត្តិទ្រព្យ ផ្ទះសំបែង គោក្របី ស្រែចំការ ជាកម្មសិទ្ធខ្លួន យកទៅអោយ «**អង្គការលើ**»។ ម្យ៉ាងទៀត ពួកកុម្មុយនិស្ត កំចាត់ បំបែក គ្រួសារ បំបែក កូនពីឳពុកម្តាយ ប្តីពីប្រពន្ធ បងពីប្អូន ម្នាក់ៗ ជាឧបករណ៍ របស់ «អង្គការលើ» ខ្លួនឯងបរិហារខ្លួនឯង កូនបរិហារបិតាមាតា ប្តីបរិហារប្រពន្ធ បងបរិហារប្អូន ទៅវិញទៅមកតាមរយះរបៀបមួយហៅ «**ស្វ័យទិះទាន**» សំដែងការស្មោះត្រង់ ចំពោះ «អង្គការ» បរិហារចុះបរិហារឡើង ល្ងាចព្រឹក ព្រឹកល្ងាច ម្នាក់ៗ ឃើញតែមាន កំហុសមិនជ្រះស្រឡះ ពី «សង្គមចាស់» ខ្នាំងនឹងបដិវត្តន៏ ត្រូវ អង្គការ កំទេចចោល ពាយព្រាជាជនខ្មែរ នាំអោយវាលប្រទេស។

សិលធម៌ធម៌ត្រជាក់ សាសនាវត្តអារ៉ាម ព្រះពុទ្ធបដិមាករណ៍ ជុំរក សតិអារម្មណ៍ របស់ជាតិខ្មែរ ព្រលឹងខ្មែរ វាដុត វាកំទេច វាបំផ្លាញ ដោយអភិទ្រោះ ឥតមានចិត្តសន្តោស ជាខ្មែរអ្នកជានោះឡើយ។ ពួកខ្មែរក្រហម និង ខ្មែរយៀកម៉ិញ ពួកនេះ វា សាហាវ ព្រៃផ្សៃជាង ខ្មាំងយួនទៅទៀត តើមានខ្មែរណាមួយទៅ អាចមានចិត្តផ្សះផ្សា មហាសាមគ្គីជាមួយ ពួកអាហុតឈាមរាស្ត្រខ្មែរ ទាំងនោះបាន ?

ជាតិខ្មែរ ធ្លាប់វាយខ្មាំងយួន តាំងពីសម័យក្រុងឧត្តុង្គ ចាប់ពី សតវត្សទី១៧ មកមុនរជ្ជកាល ព្រះអង្គដួង ពាក់កណ្តាល សតវត្ស ទី១៩ ដូចខ្មែរភាគច្រើន ធ្លាប់ដឹងរួចហើយក្នុងសង្គ្រាម ឥណ្ឌូចិនលើកទី១ និង លើកទី២ កងទ័ពជាតិ មានឈ្មោះ «ខេមរៈភូមិន្ទ្រ» រហូតដល់ «កងទ័ពជាតិខ្មែរ» បានធ្វើការតស៊ូរ ទប់ទល់ វាយខ្មាំងយួន ការពារ ឯករាជ្យបូរណភាពដែនដី និង អធិបតេយ្យភាពជាតិ ជារៀងដ៏រាប មិនដែលរួញរាទេ រក្សា កម្ពុជា និង ប្រជាពលរដ្ឋខ្មែរ រហូតទោះបីខ្ទេចខ្ទាំ របួសស្លាប់ យ៉ាងណាក្តី ក៏ទប់ទល់ជានិច្ចព្រលឹងដូនតា សន្ថិតនៅក្នុងសារពាងកាយជាតិ បានជាមិនបរាជ័យ ចាញ់ដៃ អាខ្មាំងយួនទេ មកចាញ់ល្បិចបោកប្រាស របស់ អាសត្រូវក្នុង មាន ស្តេច សីហនុ និងខ្មែរក្រហមបន្លំធ្វើ ជាជាតិ។

ចំនួន២សែននាក់ ដែលរលាយខ្លួនស្លាប់ ដោយស្នាដៃ សីហនុ និង ប៉ុល ពត ដែលបានធ្វើការ បំរើអាខ្មាំងយួន ឥតដឹងខ្លួន នាំអោយ ប្រជាពលរដ្ឋខ្មែរ អស់មានទ័ពជាតិ ពិតប្រាកដ សំរាប់ការពារ ទទួលមរណភាព ក្នុងយុទ្ធសាស្ត្រ កុម្មុយនិស្តឥណ្ឌូចិន។ ប្រមាណ២លាននាក់ ឯអ្នកសែសសល់ ពីស្លាប់ ភាគដ៏ធំ ប្រមាណ៥ ទៅ ៦លាននាក់ទៀត រស់បាត់លក្ខណៈសម្បត្តិ ជាមនុស្សធ្លាក់ខ្លួន ជាទាសអមនុស្ស សត្វពាហនៈ ដែលគេធ្វើ ការពាធា និង យកទៅទឹមតាមទំនើងចិត្ត។

វិញ្ញាណខ័ន្ធយុទ្ធជន ក្នុងជួរ «កងទ័ពជាតិ» ដែលបានបូជាជីវិត ដែលមាតាចែកអោយជា និមិត្តរូប ឯករាជភាពជាតិ បូរណភាពដែនដីជាតិ និង អធិបតីយភាពជាតិ ជាវប្បធម៌ តស៊ូរ ការពារជាតិ ប្រពៃណីយជាតិ ជាវត្ត ជា វិហ៉ារសាសនាជាតិ ត្រូវរលត់ក្នុងប៉ាឆាខ្មែរក្រហម!

## ចប់